ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



ក្រសួងសុខាភិបាល

ប្រកៈ ១៦៥ សបព/ខុសបក


# ប្រកាស

## ស្តីពី

## ការផ្តល់វិញ្ញាបនបត្រអនុញ្ញាតដាក់លក់ផលិតផលចំណីអាហារ និង ការផ្តល់វិញ្ញាបនបត្រអនាម័យផលិតផលចំណីអាហារ

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៩១៣/៩០៣ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូឆ្នាំ ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០៦ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ ២០០០ច្បាប់ ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផលទំនិញ និងសេវា

-បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ/បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល

-បានឃើញប្រកាសអន្តរក្រសួងលេខ៨៦៨ ឧរថ.ប្រក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១០ ស្តីពីការអនុវត្តន៍និងរៀបចំសម្របសម្រួលស្ថាប័នកិច្ចនៃប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារចាប់ពីកសិដ្ឋានផលិត ដល់តុបរិភោគ

-តាមតម្រូវការចាំបាច់របស់ក្រសួងសុខាភិបាល

## សម្រេច

### ប្រការ ១

ប្រកាសនេះមានគោលបំណងផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាព អនាម័យ និងសុវត្ថិភាពផលិតផលចំណីអាហាររួមមាន:

-វិញ្ញាបនបត្រអនុញ្ញាតដាក់លក់ផលិតផលចំណីអាហារ(Certificate of Free Sale)

-វិញ្ញាបនបត្រអនាម័យផលិតផលចំណីអាហារ( Health Certificate )


ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

**ប្រការ ២**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះផលិតផលចំណីអាហារដែលផលិតក្នុងព្រះរាជាណាចក្រកម្ពុជា ឬនាំចូលពីបរទេសដើម្បីធ្វើចរាចរលក់លើទីផ្សារក្នុងប្រទេស ឬនាំចេញទៅបរទេស ដើម្បីឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវប្រទេសនាំចូល។

**ប្រការ ៣**

**និយមន័យ:**

ក.**វិញ្ញាបនបត្រអនុញ្ញាតដាក់លក់ផលិតផលចំណីអាហារ** (Certificate of Free Sale):គឺជាលិខិតអនុញ្ញាតដាក់លក់ផលិតផលចំណីអាហារលើទីផ្សារក្នុងប្រទេស នាំចូលពីបរទេស និងសម្រាប់នាំចេញទៅបរទេសដែលចេញដោយក្រសួងសុខាភិបាល។

ខ.**វិញ្ញាបនបត្រអនាម័យផលិតផលចំណីអាហារ** (Health Certificate):គឺជាលិខិតដែលចេញដោយក្រសួងសុខាភិបាលបញ្ជាក់ពីលក្ខខណ្ឌតម្រូវរបស់ប្រទេសនាំចូលលើផលិតផលចំណីអាហារក្នុងប្រទេស និងសម្រាប់នាំចេញទៅបរទេស។

**ប្រការ ៤**

ម្ចាស់គ្រឹះស្ថានផលិត ក្រុមហ៊ុននាំចេញ ឬនាំចូលផលិតផលចំណីអាហារទាំងអស់ត្រូវស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដាក់លក់ផលិតផលចំណីអាហារ ឬអាចស្នើសុំវិញ្ញាបនបត្រអនាម័យផលិតផលចំណីអាហារពីក្រសួងសុខាភិបាល (នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យនិងគ្រឿងសំអាង) ។

**ប្រការ ៥**

ម្ចាស់គ្រឹះស្ថានផលិតចំណីអាហារអាចស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដាក់លក់ផលិតផលចំណីអាហារ ឬវិញ្ញាបនបត្រអនាម័យផលិតផលចំណីអាហារ នូវពាណិជ្ជនាមផ្សេងទៀតដោយរក្សារូបមន្តដដែលតម្រូវតាមការទាមទាររបស់ប្រទេសនាំចូល។

**ប្រការ ៦**

សំណុំឯកសារសម្រាប់ស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដាក់លក់ផលិតផលចំណីអាហារ ឬវិញ្ញាបនបត្រអនាម័យផលិតផលចំណីអាហារមានដូចខាងក្រោម៖

-ពាក្យស្នើសុំ (មានគំរូ)

-មានវិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អ ISO ឬវិញ្ញាបនបត្រសមមូល។

**ប្រការ ៧**

សោហ៊ុយសេវាកំណត់តាមប្រកាសរួមរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមួយក្រសួងសុខាភិបាល។

**ប្រការ ៨**

វិញ្ញាបនបត្រអនុញ្ញាតដាក់លក់ផលិតផលចំណីអាហារ(Certificate of Free Sale) និងវិញ្ញាបនបត្រអនាម័យផលិតផលចំណីអាហារ (Health Certificate) មានសុពលភាពរយៈពេល០១ឆ្នាំ។

**ប្រការ ៩**

ក្រសួងសុខាភិបាលនឹងផ្តល់វិញ្ញាបនបត្រទាំងពីរខាងលើជូនគ្រឹះស្ថានផលិត ក្រុមហ៊ុននាំចេញ ឬនាំចូលក្នុងរយៈពេល ៣០ថ្ងៃ (ថ្ងៃធ្វើការ ) នៅពេលដែលទទួលបានឯកសារគ្រប់គ្រាន់។

**ប្រការ ១០**

ក្នុងករណីដែលរកឃើញ ឬមានការប្រកាសអាសន្នពីអាជ្ញាធរមានសមត្ថកិច្ចថាផលិតផលចំណីអាហារនោះមានគ្រោះថ្នាក់ ឬប៉ះពាល់ដល់សុខភាពអ្នកបរិភោគក្រសួងសុខាភិបាលមានសិទ្ធិព្យួរទុក ឬដកហូតវិញ្ញាបនបត្រអនុញ្ញាតដាក់លក់ផលិតផលចំណីអាហារ ឬវិញ្ញាបនបត្រអនាម័យផលិតផលចំណីអាហារដែលចេញដោយក្រសួងសុខាភិបាល។ក្នុងករណីនេះម្ចាស់គ្រឹះស្ថានផលិត ក្រុមហ៊ុននាំចេញ ឬនាំចូលផលិតផលចំណីអាហារត្រូវប្រមូលត្រឡប់មកវិញនូវផលិតផលចំណីអាហារទាំងនោះ។

**ប្រការ ១១**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១២**

ខុទ្ទការល័យក្រសួងសុខាភិបាល អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសសុខាភិបាល អគ្គាធិការ នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង មន្ទីរសុខាភិបាលរាជធានីខេត្តមានភារកិច្ចណែនាំត្រួតពិនិត្យការអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិ ៣ ឆ្នាំ២០១៦

ម៉ម_ប៊ុនហេង

កន្លែងទទួល:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងទំនាក់ទំនងសភា និងអធិការកិច្ច "ដើម្បីជ្រាបជាព័ត៌មាន"
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ "ដើម្បីសហការណ៍"
- សាលារាជធានី-ខេត្ត
- ដូចប្រការ១២
- គ្រឹះស្ថានផលិត ក្រុមហ៊ុននាំចេញ នាំចូលផលិតផលចំណីអាហារ "ដើម្បីអនុវត្តន៍"
- ឯកសារ - កាលប្បវត្តិ